# ស្ថានភាពទូទៅ

អស់រយៈពេលជាងពីរទសវត្សរ៍ កម្ពុជាបានឆ្លងកាត់ស្ថានភាពនៃអស្ថេរភាពខាងនយោបាយ និងសង្គ្រាមស៊ីវិលដែលបានធ្វើឱ្យប្រទេសធ្លាក់ចូលក្នុងស្ថានភាពក្រីក្រ ។ ទោះបីជាសេដ្ឋកិច្ចសង្គមកិច្ចត្រូវបានស្តារ និងមានការអភិវឌ្ឍក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក៏ពិតមែនក៏បច្ចុប្បន្នកម្ពុជានៅតែពុំទាន់បានកាត់បន្ថយឱ្យអស់នូវភាពក្រីក្រ របស់ប្រជាពលរដ្ឋនៅឡើយ ហើយកំពុងប្រឈមទៅនឹងបញ្ហាថ្មីៗថែមទៀត ជាអាទិ៍ អត្រាកំណើនប្រជាជន ភាពអត់ការងារធ្វើ ភាពមានការងារធ្វើមិនពេញលេញ ការផ្លាស់ប្តូររចនាសម្ព័ន្ធសង្គម តម្លៃសង្គម និងសុខ-ភាពសង្គមបានក្លាយទៅជាបន្ទុកបន្ថែមទៀតសម្រាប់រាជរដ្ឋាភិបាល ។

ដោយទទួលស្គាល់ថា ការផ្តល់សេវារកការងារឱ្យធ្វើ ការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ ការរក្សាភាពសុខដុមក្នុងទំនាក់ទំនងវិជ្ជាជីវៈ ការធានាឱ្យមានបណ្តាញសុវត្ថិភាពសង្គម ការលើកកំពស់សមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ជាកត្តាគន្លឹះរួមចំណែកក្នុងការងារកាត់បន្ថយភាពក្រីក្រ ទើបក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខ នស/រកម /០១០៥/00៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២00៥ និងប្រគល់អាណត្តិជូនតាមអនុក្រឹត្យ លេខ៥២ អនក្រ/បក ចុះថ្ងៃទី0១ ខែមេសា ឆ្នាំ២00៥ របស់រាជរដ្ឋាភិបាលស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ដើម្បីធ្វើឱ្យប្រសើរឡើងនូវកំរិតជីវភាពរបស់ប្រជាពលរដ្ឋក្រសួងបានយកចិត្តទុកដាក់ ជាពិសេសទៅលើលទ្ធភាពដែលធ្វើឱ្យពលរដ្ឋទទួលបានមុខជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ហើយឈានទៅចាប់យកនូវមុខរបរសមរម្យថ្មីៗ ដែលកំពុងតែផ្លាស់ប្តូរជាលំដាប់ស្របតាមស្ថានភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានខិតខំអភិវឌ្ឍកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ ទន្ទឹមនឹងការពង្រឹងការគ្រប់គ្រង និងការផ្តល់សេវារកការងារឱ្យធ្វើ ។

សំដៅឱ្យបេសកកម្មជាយុទ្ធសាស្រ្ត ដែលរាជរដ្ឋាភិបាលកម្ពុជា បានប្រគល់ជូន សម្រេចបានជោគជ័យជាជំហានៗ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចាំបាច់ត្រូវរៀបចំឱ្យមានផែនការយុទ្ធសាស្រ្តសម្រាប់តម្រង់ទិសការអនុវត្តក្នុងរយៈពេលប្រាំឆ្នាំស្របទៅតាមផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ និងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ។